ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១១៦/១៩ - ភូមិវប្បធម៌ កម្ពុជា
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **សេង រ៉ូចហ៊ិន**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ខូន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ភូមិវប្បធម៌ កម្ពុជា**

អាសយដ្ឋាន ៖ ភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប

ទូរស័ព្ទ ៖ ០១០ ៨៤០ ៨២៣/០១០ ៧៨៧ ៣៣៤ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក នង ផៃលីម | នាយក |
| ២- លោកស្រី លឹម សុភ័ក្រ | នាយករង |
| ៣- លោកស្រី ហាម សុភា | ប្រធានរដ្ឋបាល និងធនធានមនុស្ស |
| ៤- កញ្ញា លឹម កក្កដា | បុគ្គលិករដ្ឋបាលជាន់ខ្ពស់ |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **សហជីពនិយោជិតវិស័យទេសចរណ៍នៃក្រុមហ៊ុន ភូមិវប្បធម៌ កម្ពុជា**

អាសយដ្ឋាន ៖ ភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប

ទូរស័ព្ទ ៖ ០១២/០១៦ ៣៨៨ ០០៦ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក លឹម សុផា | ប្រធានសហជីព (មូលដ្ឋាន) |
| ២- លោកស្រី រិទ្ធិ ស៊ីមល | លេខាសហជីព (មូលដ្ឋាន) |
| ៣- លោកស្រី មុំ ស្រីភ័ក្ត្រ | ហិរញ្ញឹក (មូលដ្ឋាន) |

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥.២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh ♦ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org ♦ Website: www.arbitrationcouncil.org

៤- កញ្ញា ប៉ក់ ឈឿម សកម្មជន

៥- លោក ថេង ធាប សកម្មជន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

ភាគីសហជីពនៅតែប្រកាន់ជំហរទាមទារឱ្យនិយោជកចរចាអនុសញ្ញារួមដោយស្មោះត្រង់ ជាមួយសហជីពមានភាពតំណាងបំផុត ដោយបញ្ឈប់នូវសកម្មភាពពន្យាពេល។ ភាគីនិយោជក នៅតែប្រកាន់ជំហរយកតាមលិខិតឆ្លើយតប ដោយធ្វើការចរចា នូវពេលវេលាសមស្របណាមួយ ក្នុងឆ្នាំ២០២០ ខាងមុខ។ ហើយនៅដើមឆ្នាំ២០២០ ក្រុមហ៊ុននឹងធ្វើលិខិតឆ្លើយតបមួយទៀត ដើម្បីកំណត់ថ្ងៃខែចរចា។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨១ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ (អាណត្តិទី១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា លេខ ១០៧ មកប ចុះថ្ងៃពុធ ៧រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ សណ្ឋាគារ រី ហូថែល ផ្លូវជាតិលេខ ៦ ភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប

**កាលបរិច្ឆេទសវនាការ** ៖ ថ្ងៃសុក្រ ១រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ត្រូវនឹងថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ១០ និង ៣០ នាទី ព្រឹក។

**បញ្ហានីតិវិធី៖**

នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានទទួលពាក្យបណ្តឹងរបស់សហជីពនិយោជិតស៊ែយទេសចរណ៍ នៃក្រុមហ៊ុន ភូមិវប្បធម៌ កម្ពុជា។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារបានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ ទៅតាមនីតិវិធីច្បាប់ និងបានធ្វើការផ្សះផ្សាលើការទាមទារចំនួន ១ចំណុច ប៉ុន្តែមិនទទួលបានលទ្ធផលមិនសះជានឹងគ្នាទេ។ ចំណុចមិនសះជាចំនួន ១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ភូមិវប្បធម៌ កម្ពុជា លេខ ១០៧ ម.ក.ប ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩។

THE ARBITRATION COUNCIL

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩។ ដោយសារមានលិខិតស្នើសុំពីភាគីកម្មករនិយោជិត ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើសវនាការនៅក្នុងខេត្តសៀមរាប ហេតុនេះ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ១ចំណុចនេះ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ១០ និង ៣០ នាទី ព្រឹក នៅសណ្ឋាគារ វី ហូថែល ខេត្តសៀមរាប។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វះរកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ១ចំណុចនេះ និងបានធ្វើការផ្សះផ្សាលើចំណុចវិវាទនេះបន្ថែមទៀត ប៉ុន្តែ មិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទមិនសះជាចំនួន ១ចំណុចនេះតែម្តង។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- សារណាសង្ខេបនៃការដោះស្រាយបញ្ហាសហជីពស្នើសុំ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០។

២- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ខលធីរល វីលេច រីហ្សត លេខ MOC ៩៦៩៧៨២៧៣ ពណ.ចបព ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣។

៣- លក្ខន្តិកៈក្រុមហ៊ុន ខលធីរល វីលេច រីហ្សត បានតម្កល់ទុកលេខ ៥៣៩/០៣ ពណ.ចបព ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម។

៤- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា ចុះបញ្ជិកាលេខ ៦៦៤/១៩ ខសរ ចុះថ្ងៃសុក្រ ៤រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩។

៥- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងអ្នកផ្គត់ផ្គង់ជ្រើសរើសនិយោជិតវិស័យទេសចរណ៍នៃក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា លេខ ០៩៥/១៩ កប/វប្រក ចុះថ្ងៃសុក្រ ១០កើត ខែផល្គុន ឆ្នាំចរ សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩។

៦- វិធានផ្ទៃក្នុងសម្រាប់ការចរចាអនុសញ្ញារួមរវាងក្រុមហ៊ុន ខលធីរល វីលេច រីហ្សត (ភូមិវប្បធម៌) ជាមួយ សហជីពនិយោជិតវិស័យទេសចរណ៍នៃក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា។

៧- អនុសញ្ញារួមរវាងក្រុមហ៊ុន ខលធីរល វីលេច រីហ្សត (ភូមិវប្បធម៌) ជាមួយសហជីពនិយោជិតវិស័យទេសចរណ៍នៃក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា។

៨- កំណត់ហេតុប្រជុំ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩។

៩- កំណត់ហេតុប្រជុំ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩។

១០- កំណត់ហេតុប្រជុំ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩។

១១- កំណត់ហេតុប្រជុំ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩។

១២- លិខិតឆ្លើយតបរបស់ក្រុមហ៊ុន ខលធីរល វីលេច រីហ្សត (ភូមិវប្បធម៌) ជម្រាបជូន លោកប្រធានសហជីពនៃ ភូមិវប្បធម៌កម្ពុជា ស្តីពីការពន្យាពេលពិភាក្សាលើវិធានផ្ទៃក្នុងសម្រាប់ការចរចាអនុសញ្ញារួម ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩។

១៣- លិខិតអញ្ជើញលេខ ១៨១ មកប ចុះថ្ងៃសុក្រ ៣កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប អញ្ជើញនាយកក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា ដើម្បីផ្តល់ព័ត៌មានអំពីបណ្តឹងរបស់បុគ្គលិក។

១៤- កំណត់ហេតុសួរព័ត៌មានតំណាងនិយោជក ក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា អំពីបញ្ហាទាមទារឱ្យនិយោជកចរចាអនុសញ្ញារួម ដោយស្មោះត្រង់ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩។

១៥- លិខិតអញ្ជើញលេខ ១៨៣ មកប ចុះថ្ងៃព្រហស្បតិ៍ ៩កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប អញ្ជើញនាយកក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា ដើម្បីផ្សះផ្សាវិវាទការងារ។

១៦- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩។

១៧- លិខិតឆ្លើយតបរបស់ក្រុមហ៊ុន ខលធីរល វីលេច រីហ្សត (ភូមិវប្បធម៌) ជម្រាបជូន លោកប្រធានសហជីពនៃ ភូមិវប្បធម៌កម្ពុជា ស្តីពីសំណើសុំការណាត់ជួបពិភាក្សាវិធានផ្ទៃក្នុងនៃការចរចាអនុសញ្ញារួម ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុតសហជីពនិយោជិតវិស័យទេសចរណ៍នៃក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា លេខ ០៩៥/១៩ កប/វបវក ចុះថ្ងៃសុក្រ ១០កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃតី១៥ ខែមីនា ឆ្នាំ២០១៩។

២- ពាក្យបណ្តឹងលេខ ០៥២/១៩ ចុះថ្ងៃចន្ទ ៧រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ថ្នាក់ដឹកនាំ និងសមាជិកសហជីពនិយោជិតវិស័យទេសចរណ៍នៃក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា គោរពជូន ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត

សៀមរាប ស្តីពីស្នើលោកប្រធានដោះស្រាយវិវាទរួម រវាងសហជីពមានភាពជាតំណាងបំផុតនៃក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា និងនិយោជក ក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា។

៣- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩។

៤- កិច្ចប្រជុំថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ ស្តីអំពីដំណោះស្រាយ និងការសម្រេច។

៥- កិច្ចប្រជុំថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៩ ស្តីអំពីដំណោះស្រាយ និងការសម្រេច។

៦- វិធានផ្ទៃក្នុងសម្រាប់ចរចាអនុសញ្ញារួមរវាងក្រុមហ៊ុន ខលធីរលេ វីលេច រីហ្សត (ភូមិវប្បធម៌) ជាមួយសហជីពនិយោជិតវិស័យទេសចរណ៍នៃក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា។

៧- កំណត់ហេតុប្រជុំថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩ ស្តីអំពីដំណោះស្រាយ និងការសម្រេច។

៨- កំណត់ហេតុប្រជុំថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩។

៩- លិខិតស្នើសុំលេខ ០៤៥/១៩ ចុះថ្ងៃពុធ ៤កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩ របស់ថ្នាក់ដឹកនាំសហជីពនិយោជិតវិស័យទេសចរណ៍នៃក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា គោរពជូន ប្រធានគ្រប់គ្រងទូទៅនៃក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា ស្តីពីស្នើសុំជួបពិភាក្សាលើការបង្កើតអនុសញ្ញារួម នៃក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា។

១០- កំណត់ហេតុប្រជុំថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ ស្តីអំពីដំណោះស្រាយ និងការសម្រេច។

១១- កំណត់ហេតុប្រជុំថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩។

១២- សារណារបស់សហជីពនិយោជិតវិស័យទេសចរណ៍ នៃក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា លេខ ០០១/២០ ចុះថ្ងៃចន្ទ ៤រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០។

១៣- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ខលធីរលេ វីលេច រីហ្សត លេខ MOC ៩៦៩៧៨២៧៣ ពណ.ចបព ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣។

១៤- លក្ខន្តិកៈក្រុមហ៊ុន ខលធីរលេ វីលេខ រីហ្សត បានតម្កល់ទុកលេខ ៥៣៩/០៣ ពណ.ចបព ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម។

១៥- លិខិតឆ្លើយតបរបស់ក្រុមហ៊ុន ខលធីរលេ វីលេច រីហ្សត (ភូមិវប្បធម៌) ជម្រាបជូន លោកប្រធានសហជីពនៃ ភូមិវប្បធម៌កម្ពុជា ស្តីពីការពន្យារពេលពិភាក្សាលើវិធានផ្ទៃក្នុងសម្រាប់ការចរចាអនុសញ្ញារួម ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងារថ្មីនៅក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា លេខ ១០៧ មកប ចុះថ្ងៃពុធ ៧រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩។

THE ARBITRATION COUNCIL

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ភូមិប្បែធម៌កម្ពុជា ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩។

៣- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុតសហជីពនិយោជិតវិស័យទេសចរណ៍នៃក្រុមហ៊ុន ភូមិប្បែធម៌កម្ពុជា លេខ ០៩៥/១៩ ក.ប/វ.ប/វ/ក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០០៣ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ៨កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០២ ខែមករា ឆ្នាំ២០២០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០០៤ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ៨កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០២ ខែមករា ឆ្នាំ២០២០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្ដាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ៖**

ក្រុមហ៊ុន **ខលធីរល វីលេច រីហ្សត** (ភូមិប្បែធម៌កម្ពុជា) គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងផ្នែកសេវាកម្មលក់សំបុត្រចូលទស្សនា ភូមិប្បែធម៌កម្ពុជា ទទួលបានវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ ០០០០៨២៨៥ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០០៣។ ក្រុមហ៊ុននេះមានជួលកម្មករនិយោជិតសរុបចំនួន ៣២៤នាក់ *(យោងតាមរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមរវាងក្រុមហ៊ុន ភូមិប្បែធម៌ កម្ពុជា និងសហជីពនិយោជិតវិស័យទេសចរណ៍នៃក្រុមហ៊ុន ភូមិប្បែធម៌កម្ពុជា)*។

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកចរចាអនុសញ្ញារួមដោយស្មោះត្រង់ជាមួយសហជីពមានភាពតំណាងបំផុត ដោយបញ្ឈប់នូវសកម្មភាពពន្យារពេល**

- ភាគីទាំងពីរទទួលស្គាល់ថា ៖
    - ០ សហជីពនិយោជិតវិស័យទេសចរណ៍នៃក្រុមហ៊ុន ភូមិប្បែធម៌កម្ពុជា ទទួលបានភាពជាតំណាងបំផុត នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩។
    - ០ នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៩ តំណាងសហជីពបានដាក់សំណើ ទាក់ទងនឹងការកំណត់ពេលវេលាដើម្បីរៀបចំធ្វើអនុសញ្ញារួមមាន បីដំណាក់កាលគឺ៖
        - ដំណាក់កាលទី១ ខែសីហា សហជីពដាក់ឯកសារបញ្ជូនទៅក្រុមហ៊ុន។
        - ដំណាក់កាលទី២ ខែកញ្ញា ចាប់ផ្ដើមចរចាអនុសញ្ញារួម។
        - ដំណាក់កាលទី៣ ខែតុលា ចរចាចុងក្រោយ។ ប៉ុន្តែ និយោជកបានឆ្លើយតបថា ចំពោះពេលវេលានៃការជួបប្រជុំអំពីការធ្វើអនុសញ្ញារួម និយោជកនឹងឆ្លើយតបនៅពេលវេលាមួយសមស្រប។

- នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ថ្នាក់ដឹកនាំសហជីពនេះបានដាក់ពាក្យសេចក្តីព្រាងវិធានផ្ទៃក្នុងសម្រាប់ការចរចាអនុសញ្ញារួម និងសេចក្តីព្រាងកិច្ចព្រមព្រៀងអនុសញ្ញារួម ជូនភាគីនិយោជក។
- នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៩ នៅក្នុងកិច្ចប្រជុំប្រចាំខែរវាងនិយោជក និងសហជីព និយោជកបានប្រាប់ទៅសហជីពទាក់ទងនឹងការសម្រេចលើវិធានផ្ទៃក្នុងសម្រាប់ការចរចាអនុញ្ញារួម គឺត្រូវបញ្ជូនទៅក្រុមហ៊ុន មេហ្គា អាសិត មេនេចមេន ដើម្បីរង់ចាំការពិភាក្សា និងសម្រេចជាមុនសិន។
- នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ តំណាងក្រុមហ៊ុន និងតំណាងសហជីពបានជួបជជែកពិភាក្សាគ្នាលើវិធានផ្ទៃក្នុងសម្រាប់ការចរចាអនុញ្ញារួម ប៉ុន្តែ ភាគីនិយោជកបានស្នើសុំឱ្យតំណាងសហជីពពិចារណាលើចំណុចដែលមានក្នុងអនុញ្ញារួមឡើងវិញ ហើយពិចារណាពេលវេលាថ្មីសម្រាប់ការចរចាអនុញ្ញារួម នៅពេលណាដែលក្រុមហ៊ុនមានផលចំណេញឡើងវិញ។ ការចរចានេះ មិនបានពិភាក្សាលម្អិតទៅលើខ្លឹមសារនៅក្នុងអនុញ្ញារួមនោះទេ។
- នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០១៩ តំណាងសហជីពបានដាក់លិខិតស្នើសុំជួបប្រជុំទៅនិយោជកពាក់ព័ន្ធនឹងការចរចាអនុញ្ញារួម ប៉ុន្តែ និយោជកមិនបានឆ្លើយតប។
- នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នៅក្នុងកិច្ចប្រជុំប្រចាំខែរវាងនិយោជក និងសហជីព ភាគីនិយោជកបានឆ្លើយតបពាក់ព័ន្ធនឹងការចរចាអនុសញ្ញារួមថា និយោជកមិនទាន់អាចកំណត់ថ្ងៃប្រជុំចរចាបានទេ ដោយមូលហេតុថ្នាក់ដឹកនាំក្រុមហ៊ុនត្រូវការពេលវេលា ដើម្បីរៀបចំឯកសារយោង សម្រាប់ពន្យល់ទៅថ្នាក់ដឹកនាំជាន់ខ្ពស់អំពីចំណុចនៃការស្នើសុំ និងត្រូវការពេលពន្យល់ថ្នាក់ដឹកនាំជាន់ខ្ពស់ ដើម្បីសម្រេចចិត្ត។
- នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៩ ភាគីនិយោជកបានជួបប្រជុំជាមួយតំណាងសហជីព ប៉ុន្តែនិយោជកនៅតែស្នើសុំពេលពិចារណា ហើយមិនទាន់បានបញ្ជាក់ពេលវេលាជាក់លាក់ណាមួយ ដើម្បីប្រជុំចរចាលើអនុសញ្ញារួមនោះទេ ដោយនិយោជកលើកឡើងថា សុំឆ្លើយតបវិញនៅសប្តាហ៍ក្រោយពេលចប់កម្មវិធីបុណ្យអុំទូក។
- ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ភាគីសហជីពបានដាក់ពាក្យបណ្តឹងទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ពាក់ព័ន្ធនឹងការចរចាអនុសញ្ញារួមនេះ។
- ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ និយោជកបានប្រគល់លិខិតឆ្លើយតបទៅសហជីព ដែលទាក់ទងនឹងមូលហេតុដែលនិយោជកពន្យារពេលការចរចាវិធានផ្ទៃក្នុង និងអនុសញ្ញារួមនេះ។ ដោយមូលហេតុនោះមាន៣ គឺ៖ ១. ការរៀបចំពិព័រណ៌ការងារ និងផលិតភាពជាតិ២០១៩, ២. ការបូកសរុបលទ្ធផលការងារឆ្នាំ២០១៩, និង៣. ការរៀបចំផែនការ និងទិសដៅសម្រាប់ឆ្នាំ២០២០។
- នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៩ និយោជកបានចូលរួមប្រជុំផ្សះផ្សាវិវាទការងារនៅមន្ទីរការងារខេត្តសៀមរាប ដោយនិយោជកបានជូនដំណឹងថា និយោជកនឹងធ្វើការឆ្លើយតបនៅចុងឆ្នាំ២០១៩ នេះ ពាក់ព័ន្ធនឹងពេលវេលាសមស្របដែលត្រូវប្រជុំលើវិធានផ្ទៃក្នុង និងចរចាអនុញ្ញារួម ជាមួយសហជីព។

THE ARBITRATION COUNCIL

- ០ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩ និយោជកបានចេញលិខិតឆ្លើយតបទៅសហជីពទាក់ទងនឹងពេលវេលាការប្រជុំ ដើម្បីចរចាលើវិធានផ្ទៃក្នុង តែសហជីពបានបដិសេធមិនទទួលលិខិតឆ្លើយតបរបស់ក្រុមហ៊ុន។ នៅក្នុងលិខិតឆ្លើយតបនោះ គឺនិយោជកបានសម្រេចដាក់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ដើម្បីប្រជុំពិភាក្សាសម្រេចលើវិធានផ្ទៃក្នុងសម្រាប់ការចរចាអនុសញ្ញារួម។
- ០ ភាគីទាំងពីរទទួលស្គាល់ថា ចំណុចមួយចំនួនដែលមាននៅក្នុងសេចក្តីព្រាងអនុសញ្ញារួម គឺនិយោជកកំពុងអនុវត្តហើយ ប៉ុន្តែ នៅតែចំណុចខ្លះដែលពាក់ព័ន្ធនឹងការទាមទារដំឡើងប្រាក់ឈ្នួល និងអត្ថប្រយោជន៍បន្ថែមផ្សេងៗមួយចំនួនដែលនិយោជកត្រូវពិនិត្យ និងពិចារណាដើម្បីសម្រេច។

- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា៖
  - ០ យោងតាមមាត្រា ៩៦ នៃច្បាប់ស្តីពីការងារ និងប្រកាសលេខ ៣០៣ ចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកំណត់ថា សហជីពមានភាពជាតំណាងបំផុត មានសិទ្ធិស្នើសុំចរចាបង្កើតអនុសញ្ញារួមជាមួយនិយោជក ហើយនិយោជកមានកាតព្វកិច្ចក្នុងការចរចាអនុសញ្ញារួមនេះ។
  - ០ យោងតាមមាត្រា ៦៩ និងមាត្រា ៦៣(ធ) នៃច្បាប់ស្តីពីសហជីព គឺនិយោជកបានអនុវត្តផ្ទុយពីមាត្រាទាំងពីរដោយមូលហេតុថា ភាគីសហជីពបានដាក់លិខិតស្នើសុំជួបចរចាអនុសញ្ញារួមទៅនិយោជកតាំងពីខែសីហា ឆ្នាំ២០១៩ ប៉ុន្តែ និយោជកព្យាយាមពន្យារពេលដើម្បីប្រជុំចរចាអនុសញ្ញារួម ដោយមិនព្រមកំណត់ថ្ងៃណាមួយជាក់លាក់ដើម្បីប្រជុំ និងបញ្ចប់ការប្រជុំនេះនោះទេ។ គិតមកដល់បច្ចុប្បន្ន និយោជកនៅតែមិនទាន់កំណត់កាលបរិច្ឆេទប្រជុំលើអនុសញ្ញារួម និងមិនទាន់ចាត់តាំង ឬផ្ទេរសិទ្ធិដល់តំណាងណាម្នាក់ ដើម្បីចូលរួមប្រជុំនឹងសម្រេចលើការចរចាអនុសញ្ញារួមនេះទេ។ ទង្វើនេះ គឺចាត់ទុកថានិយោជកធ្វើការរារាំងដំណើរការចរចាអនុសញ្ញារួម។
  - ០ ការដែលពន្យារពេលក្នុងការចរចាអនុសញ្ញារួមនេះ គឺធ្វើឱ្យប៉ះពាល់សិទ្ធិ និងខាតបង់នូវផលប្រយោជន៍របស់កម្មករនិយោជិត ដែលត្រូវទទួលបានពីអនុសញ្ញារួមនេះ។
  - ០ ការស្នើសុំពន្យារពេលប្រជុំអនុសញ្ញារួមនេះ គឺមិនមានហេតុផលសមរម្យ និងភាពចាំបាច់ទាល់តែសោះ ព្រោះការឆ្លើយតបសុំពន្យារពេលរបស់និយោជក គឺមានច្រើនដងណាស់។ ហេតុនេះការស្នើសុំពន្យារពេលប្រជុំចរចាអនុសញ្ញារួមនេះ គឺគ្រាន់តែជាការគេចវេសក្នុងការចរចាដោយស្មោះត្រង់តែប៉ុណ្ណោះ។
  - ០ ការលើកឡើងរបស់និយោជកដែលថា ក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា មិនមានសិទ្ធិសម្រេច ព្រោះស្ថិតនៅក្រោមក្រុមហ៊ុន មេហ្គា អាសិត មេនេចមេន គឺផ្ទុយនឹងខ្លឹមសារច្បាប់ ព្រោះក្រុមហ៊ុនភូមិវប្បធម៌កម្ពុជា មានវិញ្ញាបនបត្រ(ប៉ាតង់) និងលក្ខន្តិកៈ ដែលបញ្ជាក់ដោយក្រសួងពាណិជ្ជកម្មទទួលស្គាល់ជានីតិបុគ្គលស្របច្បាប់ ហេតុនេះ ការលើកឡើងរបស់និយោជក គឺមិនត្រឹមត្រូវឡើយ។

- ភាគីនិយោជកបានលើកឡើងថា និយោជកមិនអាចកំណត់ពេលជាក់លាក់សម្រាប់ការចរចារ និងបញ្ចប់ការចរចាទៅលើអនុសញ្ញារួមបានទេ។ យ៉ាងណាមិញ និយោជកនៅតែមានឆន្ទៈចូលរួមបង្កើត

អនុសញ្ញារួមនៅក្នុងក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា ឱ្យបានឆាប់តាមតែអាចធ្វើបាន។ ភាគីនិយោជកជំទាស់ថា ការលើកឡើងរបស់ភាគីសហជីពខាងលើ គឺមិនត្រឹមត្រូវទេ ដោយមូលហេតុថា៖

- ដោយផ្អែកតាមជំពូកទី៥ នៃច្បាប់ស្តីពីការងារ ស្តីពីអនុសញ្ញារួមនៃការងារ និយោជកបានព្យាយាមជួបជាមួយនឹងសហជីពអំពីការបង្កើតអនុសញ្ញារួមនេះហើយ ដោយព្យាយាមពន្យល់ហេតុផលផ្សេងៗ ដើម្បីកំណត់ការប្រជុំចរចាអនុសញ្ញារួមនេះ។
- និយោជកត្រូវការពេលវេលាសមរម្យ ដើម្បីរៀបចំឯកសារ និងពន្យល់ទៅដល់ថ្នាក់ដឹកនាំក្រុមហ៊ុនដើម្បីធ្វើការពិចារណា និងសម្រេចទៅលើការបង្កើតអនុសញ្ញារួមនេះ ព្រោះនៅក្នុងអនុសញ្ញារួម គឺមានចំណុចខ្លះពាក់ព័ន្ធនឹងការតំឡើងប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗដែលត្រូវការការពិចារណាពីថ្នាក់ដឹកនាំជាន់ខ្ពស់របស់ក្រុមហ៊ុន ព្រោះវាជាការចំណាយបន្ថែមរបស់ក្រុមហ៊ុន។
- បច្ចុប្បន្ន ក្រុមហ៊ុនកំពុងជួបបញ្ហាសេដ្ឋកិច្ច ដោយភ្ញៀវទេសចរណ៍ធ្លាក់ចុះ ជាហេតុធ្វើឱ្យចំណូលក្រុមហ៊ុនធ្លាក់ចុះ ហេតុនេះ ថ្នាក់ដឹកនាំក្រុមហ៊ុន គឺកំពុងព្យាយាមធ្វើយ៉ាងណារកវិធីដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ដើម្បីបង្កើនចំណូលឡើងវិញ។
- លើសពីនេះទៀត រាល់សំណើ និងលិខិតរបស់សហជីពដែលពាក់ព័ន្ធនឹងការស្នើសុំជួបប្រជុំចរចាអនុសញ្ញារួម គឺនិយោជកតែងតែទទួល និងឆ្លើយតបទៅវិញផងដែរ ហើយក៏បានប្រាប់អំពីមូលហេតុដែលនិយោជកសុំពេលខ្លះដើម្បីឱ្យថ្នាក់ដឹកនាំជាន់ខ្ពស់ពិចារណា និងចាត់តាំងអ្នកតំណាងភាគីនិយោជក ដើម្បីមកចូលរួមតុចរចាអនុសញ្ញារួមនេះជាមួយនឹងតំណាងសហជីព។
- និយោជកក៏បានចេញលិខិតឆ្លើយតបទៅភាគីសហជីព ដោយបញ្ជាក់ថា និយោជកស្នើសុំយកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ដើម្បីជួបប្រជុំជាមួយនឹងសហជីពដើម្បីពិភាក្សា និងសម្រេចទៅលើវិធានផ្ទៃក្នុងសម្រាប់ការចរចាអនុសញ្ញារួម។ និយោជកក៏បានបញ្ជាក់ទៀតថា បន្ទាប់ពីពិភាក្សា និងសម្រេចលើវិធានផ្ទៃក្នុងសម្រាប់ការចរចាអនុសញ្ញារួមចប់សព្វគ្រប់ គឺនិយោជកនឹងប្រជុំពិភាក្សាគ្នាបន្តអំពីសេចក្តីព្រាងអនុសញ្ញារួមនេះតែម្តង។

- ភាគីនិយោជកបានបញ្ជាក់ថា ជាការអនុវត្តនៅក្នុងក្រុមហ៊ុន ពាក់ព័ន្ធនឹងការសម្រេចទាក់ទងនឹងការចំណាយផ្សេងៗរបស់ក្រុមហ៊ុន គឺនិយោជកត្រូវការពេលវេលា ២ខែ ទៅ ៤ខែ ដើម្បីពិនិត្យ និងសម្រេច។
- ភាគីកម្មករនិយោជិតបានបន្តលើកឡើងថា ភាគីសហជីព គឺចង់ឱ្យនិយោជកជួបចរចាអនុសញ្ញារួម ឱ្យបានចប់សព្វគ្រប់នៅក្នុងរយៈពេល ៤ខែ ទៅ ៥ខែ យ៉ាងយូរ ព្រោះគិតចាប់ពីពេលដាក់ពាក្យស្នើសុំតាំងពីខែសីហា ឆ្នាំ២០១៩ មកដល់បច្ចុប្បន្ននេះ គឺមានរយៈពេលយូរហើយ និយោជកនៅតែពន្យារពេលមិនព្រមកំណត់ថ្ងៃជួបប្រជុំចរចាអនុសញ្ញារួម និងសម្រេចនោះទេ។ ទង្វើទាំងនេះហើយដែលចាត់ទុកថា និយោជកចរចាអនុសញ្ញារួមដោយមិនស្មោះត្រង់។

**ហេតុផលនៃសេចក្តីសម្រេច ៖**

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកចរចាអនុសញ្ញារួមដោយស្មោះត្រង់ជាមួយសហជីពមានភាពតំណាងបំផុត ដោយបញ្ចប់នូវសកម្មភាពពន្យារពេល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចចរចាអនុសញ្ញារួមដោយស្មោះត្រង់ជាមួយសហជីពមានភាពតំណាងបំផុត ដោយបញ្ឈប់នូវសកម្មភាពពន្យារពេលនៃការចរចាអនុសញ្ញារួម ដែរឬទេ?

កថាខណ្ឌទី១ នៃមាត្រា ៥៤ ថ្មី នៃច្បាប់ស្តីពីសហជីព បានចែងថា ៖ *"ភាពជាតំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន។ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្តាច់មុខ"*។

យោងតាមកថាខណ្ឌទី២ និងទី៣ មាត្រា ៥៣ ស្តីពីគោលការណ៍នៃភាពសុច្ចរិត និងស្មោះត្រង់ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ បានចែងថា ៖

*"ករណីយកិច្ចតម្រូវឱ្យមានភាពស្មោះត្រង់នេះ រាប់បញ្ចូលទាំងករណីយកិច្ចដែលជាប់ទាក់ទងនឹងសហជីពដែលត្រូវបានបញ្ជាក់ថាមានភាពជាតំណាងបំផុត ដើម្បីជួប និងកោះប្រជុំឱ្យបានទាន់ពេល និងឱ្យបានញាប់ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួមទាក់ទងនឹងប្រការផ្សេងៗ និងលក្ខខណ្ឌការងារ ស្របទៅតាមបទប្បញ្ញត្តិនានានៃច្បាប់នេះ ក៏ដូចជាការពិចារណាទៅលើសំណោះសម្រាប់ដោះស្រាយបណ្តឹងតវ៉ា ឬសំណួរទាំងឡាយដែលកើតចេញពីកិច្ចព្រមព្រៀង។ ករណីយកិច្ចនេះ មានលើសពីកិច្ចប្រជុំ និងការពិគ្រោះយោបល់ជាធម្មតា ហើយរាប់បញ្ចូលទាំងការផ្តល់ឱ្យសហជីពដែលមានភាពជាតំណាងបំផុតនូវលក្ខណៈងាយស្រួលទាំងឡាយ ដើម្បីធ្វើការចរចាផ្តល់នូវព័ត៌មានទាំងអស់ពាក់ព័ន្ធនឹងការចរចាដែលបានស្នើឡើងដោយសហជីព និងការអនុវត្តកិច្ចសន្យា ឬអនុស្សរណៈនៃការយោគយល់គ្នាជាលាយលក្ខណ៍អក្សរ ដោយដាក់បញ្ចូលនូវកិច្ចព្រមព្រៀងទាំងនេះ ប្រសិនបើមានការស្នើសុំពីភាគីណាមួយ ប៉ុន្តែ មិនតម្រូវឱ្យនិយោជក ឬសមាគមនិយោជកមានករណីកិច្ចយល់ព្រមទៅនឹងសំណើជាក់លាក់ណាមួយដែលស្នើឡើងដោយសហជីពឡើយ។*

*ភាគីទាំងពីរនៃការចរចា ត្រូវគោរពគោលការណ៍នៃភាពសុច្ចរិត និងស្មោះត្រង់"*។

មាត្រា ៧១ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ បានចែងថា៖ *"ភាគីនៃកិច្ចចរចាអនុសញ្ញារួមត្រូវតែទទួលបាននូវសិទ្ធិពេញលេញពីសមាជិករបស់ខ្លួន តាមរយៈការប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬការប្រគល់សិទ្ធិដែលមានចែងក្នុងច្បាប់នេះ ដើម្បីធ្វើការ និងសម្រេចបានកិច្ចចរចា។ ការជ្រៀតជ្រែក ការញុះញង់ និងការរំខានពីបុគ្គលទាំងឡាយដែលមិនមានការពាក់ព័ន្ធនឹងអនុសញ្ញារួមត្រូវបានហាមឃាត់"*។

កថាខណ្ឌទី៣ មាត្រា ៦៩ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ បានចែងថា *"បទបញ្ញត្តិនៃអនុសញ្ញារួមអាចនឹងមានលក្ខណៈប្រសើរដល់បុគ្គលិកធ្វើការតាមផ្លូវអាកាស និងសមុទ្រ និងកម្មករនិយោជិតជាងបទប្បញ្ញត្តិនៃច្បាប់ និងបទបញ្ជាទាំងឡាយជាធរមាន។ ...ការទាមទារទាំងអស់ ទាំងរបស់និយោជក ទាំងរបស់បុគ្គលិក ទាំងរបស់កម្មករនិយោជិតចំពោះសិទ្ធិប្រយោជន៍នានា និងលក្ខខណ្ឌការងារដែលខុសពីច្បាប់ បទបញ្ជា និងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ឬគ្រឹះស្ថានត្រូវដោះស្រាយតាមរយៈដំណើរការចរចាអនុសញ្ញារួមមួយដ៏ត្រឹមត្រូវ"*។

យោងតាមមាត្រា ៥៣, មាត្រា៥៤, មាត្រា ៦៩ និងមាត្រា ៧១ នៃច្បាប់ស្តីពីសហជីព ដែលបានលើកឡើងខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហជីពដែលមានភាពជាតំណាងបំផុត មានសិទ្ធិស្នើសុំចរចាអនុសញ្ញារួម ជាមួយនឹងនិយោជក។ និយោជកត្រូវចូលរួមចរចាអនុសញ្ញារួម ជាមួយនឹងសហជីពដែលមានភាពជាតំណាងបំផុត ហើយភាគីទាំងពីរត្រូវគោរពគោលការណ៍នៃភាពសុច្ចរិត និងភាពស្មោះត្រង់ក្នុងការចរចាអនុសញ្ញារួមនេះ។ ករណីនេះពាក្យថាភាពស្មោះត្រង់នោះ គឺរួមបញ្ចូលទាំងការទទួលស្គាល់សិទ្ធិរបស់សហជីពដែលមានភាពតំណាងបំផុត ជួបប្រជុំឱ្យទាន់ពេល និងញាប់ធ្វើយ៉ាងណាឱ្យការប្រជុំនោះញាប់

THE ARBITRATION COUNCIL

សម្រេចនូវគោលបំណងនៃអនុសញ្ញារួម ជៀសវាងការពន្យារពេលចរចាដោយគ្មានមូលហេតុ និង ត្រូវចូលរួមចរចាដោយសមូហភាព។

យោងតាមអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីតំណាងសហជីពដែលមានភាពជាតំណាងបំផុត បានដាក់ពាក្យស្នើសុំចរចាអនុសញ្ញារួម និងបានដាក់សេចក្តីព្រាងវិធានផ្ទៃក្នុងសម្រាប់ការចរចាអនុសញ្ញារួម និងសេចក្តីព្រាងអនុសញ្ញារួម ទៅភាគីនិយោជក តាំងពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ហើយគិតមកដល់ថ្ងៃសវនាការ ភាគីទាំងពីរមិនទាន់បានជួបប្រជុំគ្នា និងសម្រេចលើវិធាននៃការចរចា និងខ្លឹមសារនៃអនុសញ្ញារួមនោះទេ។

យោងតាមមាត្រា ៥៤, មាត្រា ៥៣, មាត្រា ៦៩ និងមាត្រា ៧១ នៃច្បាប់ស្តីពីសហជីពខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកក៏មានឆន្ទៈក្នុងការជួបប្រជុំដើម្បីចរចាអនុសញ្ញារួមដែរ ដោយសាររាល់ការស្នើសុំរបស់ភាគីសហជីពពាក់ព័ន្ធនឹងការចរចាអនុសញ្ញារួម គឺនិយោជកបានឆ្លើយតប និងបានជួបប្រជុំខ្លះជាមួយសហជីព ដើម្បីលើកពីមូលហេតុដែលនិយោជកមិនអាចកំណត់ពេលវេលាជួបប្រជុំចរចាអនុសញ្ញារួម ឱ្យបានឆាប់រហ័ស។ ម្យ៉ាងវិញទៀត និយោជកបានកំណត់យកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ជាថ្ងៃដើម្បីប្រជុំសម្រេចលើវិធានផ្ទៃក្នុងសម្រាប់ការចរចាអនុសញ្ញារួម ហើយក្រោយពីសម្រេចលើវិធានផ្ទៃក្នុងនេះរួច និយោជកនឹងបន្តប្រជុំចរចាលើខ្លឹមសារដែលមាននៅក្នុងអនុសញ្ញារួមនោះតែម្តង។ យ៉ាងណាមិញ ភាគីសហជីពនៅតែមិនព្រមនឹងកាលបរិច្ឆេទដែលនិយោជកបានលើកឡើង ដោយមូលហេតុថា ពេលវេលានោះវាយូរសម្រាប់ពួកគាត់ ហើយសហជីពបារម្ភថា មិនដឹងពេលណាទើបការចរចាចប់សព្វគ្រប់ ព្រោះនិយោជកចេះតែពន្យារពេលជាបន្តបន្ទាប់។

ក្នុងករណីនេះ គិតពីថ្ងៃដែលកម្មករនិយោជិតបានដាក់ពាក្យស្នើសុំចរចា ពីខែសីហា ឆ្នាំ២០១៩ មកដល់ពេលបច្ចុប្បន្ននេះ គឺមានរយៈពេលប្រមាណជា ៦ខែហើយ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានករណីយកិច្ចចូលរួម និងកំណត់ពេលវេលាប្រជុំឱ្យបានឆាប់រហ័សក្នុងការចរចាអនុសញ្ញារួមជាមួយភាគីសហជីពដែលមានភាពជាតំណាងបំផុត។ យោងតាមអង្គហេតុ ភាគីទាំងពីរក៏ទទួលស្គាល់ដែរថា ចំណុចមួយចំនួនដែលមាននៅក្នុងខ្លឹមសារនៃអនុញ្ញារួម ដែលស្នើឡើងដោយភាគីតំណាងសហជីព គឺនិយោជកកំពុងអនុវត្តហើយ ហេតុនេះ នៅសល់តែចំណុចខ្លះដែលពាក់ព័ន្ធនឹងការដំឡើងប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗតែប៉ុណ្ណោះ។ ចំណែក និយោជកក៏បានលើកឡើងដែរថា ជាទូទៅពាក់ព័ន្ធនឹងការចំណាយបន្ថែមផ្សេងៗរបស់ក្រុមហ៊ុន គឺនិយោជកត្រូវការពេលវេលា ២ខែ ទៅ ៤ខែ ដើម្បីធ្វើការពិនិត្យ និងសម្រេច។

លើសពីនេះទៀត ប្រការ៣៤ នៃប្រកាស ០៩៩ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា៖ *"...ក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារ និងប្រកាសនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសិទ្ធិ និងអំណាចក្នុងការសម្រេច ឱ្យភាគីវិវាទផ្តល់នូវសំណងជួសជុលវេណី ឬសំណងខូចខាតដែលមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ ដោយរួមទាំងការ ៖*

...

*ង. បញ្ជាឱ្យធ្វើការចរចា*

.....

*ឆ. បង្កើតលក្ខខណ្ឌទាំងឡាយសម្រាប់អនុសញ្ញារួម*

*..."។*

យោងតាមការបកស្រាយច្បាប់ និងអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ដើម្បីឱ្យការចរចាអនុសញ្ញារួម ប្រព្រឹត្តទៅបានឆាប់រហ័ស និងសម្រេចបានគោលបំណងនៃអនុសញ្ញារួម និយោជកត្រូវចូលរួមប្រជុំចរចា ជាមួយភាគីសហជីព និងកំណត់ពេលវេលាចរចាអនុសញ្ញារួមឱ្យបានឆាប់ និងចប់ក្នុងរយៈពេល ៦ខែ ដោយមូលហេតុថា ជាទូទៅការអនុវត្តរបស់និយោជកពាក់ព័ន្ធនឹងការចំណាយបន្ថែមផ្សេងៗ និយោជកប្រើពេលវេលាតែ ២ខែ ទៅ ៤ខែ ប៉ុណ្ណោះ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការកំណត់រយៈពេល ៦ខែ សម្រាប់ការចរចាអនុសញ្ញារួមឱ្យចប់សព្វគ្រប់ គឺជារយៈពេលមួយដែលសមរម្យសម្រាប់ភាគីទាំងពីរ។

ហេតុនេះ យោងតាមប្រការ ៣៤ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបង្គាប់ឱ្យនិយោជកចូលរួមប្រជុំចរចារអនុសញ្ញារួម និងធ្វើយ៉ាងណាឱ្យការចរចាអនុសញ្ញារួមនេះចប់សព្វគ្រប់នៅក្នុងរយៈពេល ៦ខែ គិតចាប់ពីថ្ងៃដែលសេចក្តីបង្គាប់នេះ ចូលជាស្ថាពរ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

- បង្គាប់ឱ្យនិយោជកចូលរួមប្រជុំចរចារអនុសញ្ញារួម ជាមួយភាគីសហជីព និងធ្វើយ៉ាងណាឱ្យការចរចាអនុសញ្ញារួមនេះចប់សព្វគ្រប់នៅក្នុងរយៈពេល ៦ខែ គិតចាប់ពីថ្ងៃដែលសេចក្តីបង្គាប់នេះ ចូលជាស្ថាពរ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **សេង ឌួចហ៊ុន**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **ឡូន ស៊ីផាន់**

ហត្ថលេខា ៖------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL